# III - ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០១

## ប្រកាសអន្តរក្រសួង

## លេខ ០០៦ ប្រកសហវ

## ស្តីពីការកំណត់ថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់

===

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១០៩៥/០១ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សំរេច

**ប្រការ ១ :** ការធ្វើអាជីវកម្មជីកយកថ្មសំភារៈសំណង់ទាំងអស់ ត្រូវបង់ជូនរដ្ឋនូវថ្លៃវត្ថុធាតុដើម ។ ថ្មសំភារៈ សំណង់រួមមាន : ថ្មសំណង់ គ្រួស ខ្សាច់ ដី ដីក្រហម ( ឡាតេរិត ) និងដីឥដ្ឋ ។

**ប្រការ ២ :** អាជីវករជាម្ចាស់ការដ្ឋាន ជាអ្នកទទួលខុសត្រូវបង់ថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់ដែលជីកយក ឬលក់ចេញ ។

**ប្រការ ៣ :** ថ្លៃវត្ថុធាតុដើមលើការធ្វើអាជីវកម្មជីកយកថ្មសំភារៈសំណង់ ត្រូវកំណត់តាមអត្រាដូចខាងក្រោម :

១- ០.៦ ដុល្លារអាមេរិក/ម៉ែត្រគ្រីគុណ ចំពោះថ្មសំណង់ដែលជាថ្មបំបែកគ្រប់ប្រភេទមានទំហំចាប់ពី ១ សម. × ២ សម. ឡើងទៅ

២- ០.៤ ដុល្លារអាមេរិក/ម៉ែត្រគ្រីគុណ ចំពោះគ្រួសក្រាវែត

៣- ០.២ ដុល្លារអាមេរិក/ម៉ែត្រគ្រីគុណ ចំពោះថ្មសំណង់ដែលជាថ្មបំបែកគ្រប់ប្រភេទមានទំហំតូចជាង ១ សម × ២ សម ខ្សាច់សំណង់ និង ដីក្រហម ( ឡាតេរីត ) ។

៤- ០.១ ដុល្លារអាមេរិក/ម៉ែត្រគ្រីគុណ ចំពោះផលិតផលសំរេចពីដីឥដ្ឋដែលរួមមាន ឥដ្ឋ ក្បឿង និងផលិតផលពីដីឥដ្ឋផ្សេងៗទៀតលើកលែងតែផលិតផលកុលាលភាជនី

៥- ០.១ ដុល្លារអាមេរិក/ម៉ែត្រគ្រីគុណចំពោះអាចម៍ដីដែលជីកក្នុងបំណងពាណិជ្ជកម្មក្រៅពីការធ្វើអាជីវកម្មដែលមានចែងក្នុងចំណុច ៤ ប្រការ ៣ ខាងលើ ។

**ប្រការ ៤ :** ចំណូលពីថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់ ត្រូវបានបែងចែក និងបង់ចូលថវិការដ្ឋ ៨០ ភាគរយ ថវិកាខេត្ត ក្រុង ២០ ភាគរយ និងអនុញ្ញាតអោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដកវិញចំនួន១០ ភាគរយសំរាប់ចំណាយក្នុងការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និង ធនធានរ៉ែ ។

**ប្រការ ៥ :** អាជីវករត្រូវបង់ថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់នៅរតនាគារខេត្ត ក្រុង ដែលខ្លួនបោះទីតាំងការដ្ឋានផលិតកម្ម និង អាជីវកម្មដោយផ្អែកតាមបញ្ជាចំណូល ( សាលាកប័ត្របង់ចំណូល ) របស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត ក្រុង ។

**ប្រការ ៦ :** ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការកំណត់ និងគ្រោងខ្ទង់ចំណូលនេះនៅពេលធ្វើការពិភាក្សាថវិកាប្រចាំឆ្នាំនីមួយៗ ដោយកត់ត្រាដូចខាងក្រោម :

សរុបនៃសាលាប័ត្របង់ចំណូលរបស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ហើយសាលាប័ត្របង់ចំណូលនេះត្រូវភ្ជាប់តាមជាមួយនូវលិខិតយុទ្ធការនៅពេលមកចុះទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ។

**ប្រការ ១១ :** អាជីវករដែលជាប់កាតព្វកិច្ចបង់ថ្លៃវត្ថុធាតុដើមផ្គត់ផ្គង់ភារៈសំណង់ ត្រូវបង់ពន្ធផ្សេងៗទៀតតាមច្បាប់សារពើពន្ធជាធរមាន ។

**ប្រការ ១២ :** កាតព្វកិច្ចហិរញ្ញវត្ថុដែលមានចែងក្នុងកិច្ចព្រមព្រៀង ស្តីពីការធ្វើអាជីវកម្មវត្ថុធាតុដើមផ្គត់ផ្គង់សំភារៈសំណង់រវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងអាជីវករដែលមានពីមុន ហើយផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៣ :** អង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

**ប្រការ ១៤ :** ប្រកាសនេះ មានប្រសិទ្ធភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| ទេសរដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **គាត ឈន់** | **ស៊ុយ សែម** |

***

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

## ប្រកាស

## ប្រកាសលេខ ០៤ អយកឧប្រក

## ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ " ឬស្សីសាញ់ " មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

===

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី